ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ

# លិខិតជូនពរ

## សូមគោរពជូន

## សម្តេចពិជ័យសេនា ទៀ បាញ់
## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងការពារជាតិ

សម្តេចពិជ័យសេនា ជាទីគោរពដ៏ខ្ពង់ខ្ពស់

ក្នុងឱកាសចម្រើនជន្មាយុរបស់ សម្តេច នៅថ្ងៃទី០៥ ខែវិច្ឆិកា ឆ្នាំ២០២០ នេះ យើងខ្ញុំថ្នាក់ដឹកនាំ និងមន្ត្រីរាជការក្រសួងមុខងារសាធារណៈ មានសេចក្តីសប្បាយរីករាយ សូមចូលរួមអបអរសាទរ និងជូនពរ សម្តេចពិជ័យសេនា សូមសម្រេចប្រកបដោយសុខភាពល្អបរិបូរណ៍ កាយពលមាំមួន បញ្ញាញាណវាងវៃ និងជន្មាយុយឺនយូរ។

ឆ្លៀតក្នុងឱកាសដ៏វិសេសវិសាលនេះ យើងខ្ញុំទាំងអស់គ្នាសូមសម្តែងនូវការកោតសរសើរដោយស្មោះ ចំពោះ សម្តេចពិជ័យសេនា ដែលបានខិតខំប្រឹងប្រែងបំពេញភារកិច្ចអស់ពីកម្លាំងកាយចិត្ត ប្រាជ្ញា ស្មារតី ចូលរួមចំណែកជាមួយរាជរដ្ឋាភិបាល ដែលមាន សម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីជាប្រមុខ ដើម្បីដឹកនាំកសាងប្រទេសជាតិឱ្យមានសន្តិភាព និងការអភិវឌ្ឍលើគ្រប់វិស័យ។

ជាថ្មីម្តងទៀត យើងខ្ញុំទាំងអស់គ្នាសូមអនុញ្ញាតគោរពជូនពរ សម្តេចពិជ័យសេនា និង លោកជំទាវ បុត្រធីតា ព្រមទាំងចៅប្រុស ចៅស្រីជាទីស្រលាញ់របស់ សម្តេច សូមបានប្រកបដោយ ពុទ្ធពរទាំង ៤ ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម សម្តេចពិជ័យសេនា មេត្តាទទួលនូវការគោរពដ៏ជ្រាលជ្រៅ និងខ្ពង់ខ្ពស់បំផុតអំពីយើងខ្ញុំ។

ថ្ងៃ ព្រហស្បតិ៍ ៤រោច ខែកត្តិក ឆ្នាំជូត ទោស័ក ព.ស.២៥៦៤
រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែវិច្ឆិកា ឆ្នាំ ២០២០

រដ្ឋមន្ត្រី

ហ៊ុំ សុខា

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh